**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ :** ៥៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ សម្រាប់ប្រើដើម្បីបំពេញការងារចុះអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យរ៉ែ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ មានដូចខាងក្រោម៖

- សម្លៀកបំពាក់
- មួក និង
- សញ្ញាសក្តិ។

**មាត្រា៣ .-**

សម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់យកប្រភេទសាច់ក្រណាត់និងពណ៌កាគី លើកលែងតែនៅក្នុងទីតាំងដែលត្រូវទាមទារការការពារពិសេសដែលនឹងត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ផ្នែកទី១
## សម្លៀកបំពាក់

**មាត្រា៤ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ចំពោះបុរស**

- អាវដៃខ្លី កបើក ថ្មេរឌុប ប៉ូលស្មាសងខាងជីបចង្កេះ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួន ហើយមានហោប៉ៅចំនួន៤(បួន) ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរបត់ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍និងឡេវចំនួន៦(ប្រាំមួយ)គ្រាប់
- អាវដៃវែង កបើក ថ្មេរឌុប ប៉ូលស្មាសងខាង ជីបភ្លីខាងមុខ២(ពីរ) ពីក្រោមរហូតដល់លើសម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួន ហើយមានហោប៉ៅចំនួន៤(បួន) ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានជីបភ្លីចំនួន២(ពីរ) មានឆែកចំកណ្តាលនៃអាវនិងឡេវចំនួន៦(ប្រាំមួយ)គ្រាប់

- ខោជើងវែងមានពណ៌ដូចអាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខ២(ពីរ) មានហោប៉ៅចំនួន៣(បី) ហោប៉ៅខាងក្រោយ១(មួយ)ដេរថ្នេរបង្កប់មានគម្របរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវចំនួន១(មួយ)គ្រាប់ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ
- ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅនិងមានស្រោមជើងពណ៌ខ្មៅ និង
- ស្បែកជើងឃ្លុប កវែង ពណ៌ខ្មៅនិងមានស្រោមជើងពណ៌ខ្មៅ។

**២- ចំពោះនារី**

- អាវម៉ូតដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូតដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ
- ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅនិងមានស្រោមជើងពណ៌ខ្មៅ និង
- ស្បែកជើងឃ្លុប កវែង ពណ៌ខ្មៅ និងមានស្រោមជើងពណ៌ខ្មៅ។

គំរូសម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ សម្រាប់បុរសត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ សម្រាប់នារីត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## ផ្នែកទី២

## មួក

**មាត្រា៥ .-**

មួករបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ជាមួកកាស្កេតធ្វើពីសាច់ក្រណាត់និងពណ៌ដូចសម្លៀកបំពាក់ ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាសទំហំកម្ពស់៧,៨(ប្រាំពីរក្បៀសប្រាំបី)សង់ទីម៉ែត្រ ទទឹង៦,៨(ប្រាំមួយក្បៀសប្រាំបី)សង់ទីម៉ែត្រ។ នៅខាងក្រោមព្រះរាជសង្ហារនេះ មានកណ្តាប់វណ្ណប៉ានពណ៌ខ្មៅនិងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។ នៅផ្នែកខាងក្រោមកណ្តាប់វណ្ណប៉ានពណ៌ខ្មៅមានខ្សែឆ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្នាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២(ពីរ)គ្រាប់។ ក្បាំងមួកមានពណ៌ខ្មៅ ផ្នែកខាងមុខនៃក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីដល់ជើងមួកឬពាក់កណ្តាលជើងមួក។ គែមរបស់ក្បាំងមួកមានវណ្ណទំហំ០,៥(សូន្យក្បៀសប្រាំ)សង់ទីម៉ែត្រ ពណ៌មាសព័ទ្ធដល់ជើងមួក ឬគ្មានតាមថ្នាក់នីមួយៗ។

មួកកាស្កេតនេះត្រូវបានកំណត់ជា៤(បួន)ថ្នាក់ដូចខាងក្រោម៖

**១- ថ្នាក់អគ្គនាយក** : ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ណប៉ានពណ៌ខ្មៅមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែឆ្នាក់វេញពណ៌មាស ហើយនៅចុង

សងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង៦(ប្រាំមួយ) ទងពណ៌មាស ទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក និងគែមរបស់ក្បាំងមួកមានវណ្ឌទំហំ០,៥(សូន្យក្បៀសប្រាំ)សង់ទីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

២- **ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន** : ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ឌប៉ានពណ៌ខ្មៅមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង៦(ប្រាំមួយ)ទងពណ៌មាស ទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក។

៣- **ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ** ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ឌប៉ានពណ៌ខ្មៅមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង៤(បួន)ទងពណ៌មាស ទម្រង់ស្នែងក្របី។

៤- **ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី:** ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ឌប៉ានពណ៌ខ្មៅមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង២(ពីរ)ទងពណ៌មាសទម្រង់ស្នែងក្របី។

គំរូមួករបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## សញ្ញាសក្តិ

**មាត្រា៦ .-**

សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែសម្រាប់ពាក់លើស្មាអាវសងខាង ត្រូវបានកំណត់ជា៤(បួន)ថ្នាក់ដូចខាងក្រោម៖

១- **ថ្នាក់អគ្គនាយក:** សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីអធិការកិច្ចរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសប្រាំខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ក.ធ.រ.**"។

២- **ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន:** សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជ

សង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីអធិការកិច្ចរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសបីខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ក.ធ.រ.**"។

៣. **ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ:** សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីអធិការកិច្ចរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសមួយខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ក.ធ.រ.**"។

៤. **ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី:** សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីអធិការកិច្ចរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ក.ធ.រ.**"។

គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់
### ផ្នែកទី១
### សញ្ញាសម្គាល់

**មាត្រា៧ .-**

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម៖

១. សញ្ញាពាក់នៅលើដើមដៃអាវខាងស្តាំ ជាសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពលធ្វើពីសាច់ក្រណាត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨(ប្រាំបី)សង់ទីម៉ែត្រ។

២. សញ្ញាពាក់នៅលើដើមដៃអាវខាងឆ្វេង ជាសញ្ញាសម្គាល់របស់អគ្គនាយកដ្ឋានធនធានរ៉ែនិងអង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពល ធ្វើពីសាច់ក្រណាត់ក្រាស់រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨(ប្រាំបី)សង់ទីម៉ែត្រ។

៣. សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវ សម្គាល់សញ្ញារបស់អគ្គនាយកដ្ឋានធនធានរ៉ែនិងរបស់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពលដូចខាងក្រោម៖

- រូបញញួរនិងប៉ែលដាក់ខ្វែងគ្នាជាសញ្ញាគុណនិងមានពណ៌ទឹកមាសសម្រាប់អគ្គនាយកដ្ឋានធនធានរ៉ែ
- រូបប៊ិចនិងកែវពង្រីកដាក់ខ្វែងគ្នាជាសញ្ញាគុណនៅពីលើសៀវភៅនិងមានពណ៌មាសសម្រាប់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពល។

៤- ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមានបណ្តោយប្រវែង៩,៥(ប្រាំបួនក្បៀសប្រាំ)សង់ទីម៉ែត្រ ទទឹង២(ពីរ)សង់ទីម៉ែត្រ ដែលសរសេរអក្សរពណ៌ទឹកមាសនិងពាសដោយជ័ររឹងថ្លាមានផ្ទៃពណ៌ខ្មៅ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ០,១៥(សូន្យក្បៀសដប់ប្រាំ)សង់ទីម៉ែត្រ។ ប៉ែកខាងស្តាំដៃនៃស្លាកឈ្មោះមានសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពល និងប៉ែកខាងឆ្វេងមានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានឈ្មោះអង្គភាពរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ។

៥- ស្លាកសញ្ញានគរបាលយុត្តិធម៌ក្រសួងរ៉ែនិងថាមពលមានរូបសញ្ញាសម្គាល់ក្រសួងរ៉ែនិងថាមពលធ្វើពីលោហធាតុរាងមូលប៉ោងទំហំអង្កត់ផ្ចិត៥(ប្រាំ)សង់ទីម៉ែត្រ ពណ៌មាសផុសឡើង ភ្ជាប់លើបន្ទះស្បែកពណ៌ខៀវចាស់សម្រាប់ព្យួរនៅហោប៉ៅអាវលើខាងស្តាំ។ នៅផ្ទៃរង្វង់មានសរសេរអក្សរខ្មែរពណ៌មាស "នគរបាលយុត្តិធម៌" នៅចុងអង្កត់ផ្ចិតនៃពាក្យនេះមានលម្អដោយផ្កាចន្ទន៍។

គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## បណ្ណសម្គាល់ខ្លួន

**មាត្រា៨ .-**

មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវមានបណ្ណសម្គាល់ខ្លួនដើម្បីបញ្ជាក់អត្តសញ្ញាណក្នុងពេលបំពេញភារកិច្ចដែលចេញដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

បណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវមានអត្តលេខ ឈ្មោះ បិទរូបថត ចុះហត្ថលេខា និងបោះត្រាជាផ្លូវការរបស់ក្រសួងរ៉ែនិងថាមពល។

**មាត្រា៩ .-**

ក្នុងពេលបំពេញបេសកកម្មមន្ត្រីអធិការកិច្ចធនធានរ៉ែ ត្រូវស្លៀកពាក់ ឯកសណ្ឋាន សញ្ញាសម្គាល់ និងមានបណ្ណសម្គាល់ខ្លួនព្រមទាំងលិខិតបញ្ជាបេសកកម្ម។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចនៃក្រសួងរ៉ែនិងថាមពល ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា១០ .-**

ឯកសណ្ឋាននិងសញ្ញាសម្គាល់ដូចបានកំណត់ក្នុងអនុក្រឹត្យនេះត្រូវបានផ្តល់ជូនមន្ត្រីអធិការកិច្ចនៃក្រសួងរ៉ែនិងថាមពលក្នុងម្នាក់ៗចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ តាមទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានវិភាជជូន។

គំរូឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១១ ៈ**

ជនណាក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋាននិងសញ្ញាសម្គាល់មន្ត្រីអធិការកិច្ចធនធានរ៉ែរបស់ក្រសួងរ៉ែនិងថាមពល ដូចមានកំណត់ក្នុងអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២ ៈ**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៣ ៈ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ...៤៣...អនក្រ.បក.....ចុះថ្ងៃទី.....២.....ខែ...មេសា.....ឆ្នាំ...២០១៩....**

## ស្ដីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

### ១- គំរូសម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

#### ១.១- ឯកសណ្ឋានបុរសសម្រាប់អគ្គនាយកដ្ឋានធនធានរ៉ែ

**គំរូអាវដៃខ្លី អាវដៃវែង និងខោ**

**អាវដៃខ្លី**



**អាវដៃវែង**



ខោ



## ១.២- ឯកសណ្ឋាននារីសម្រាប់អគ្គនាយកដ្ឋានធនធានរ៉ែ

### គំរូអាវដៃខ្លី អាវដៃវែង និងខោ

អាវដៃខ្លី



## អាវដៃវែង



## ខោ



## ១.៣- ឯកសណ្ឋានបុរសសម្រាប់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពល

### គំរូអាវដៃខ្លី អាវដៃវែង និងខោ

### អាវដៃខ្លី



### អាវដៃវែង



## ខោ



## ១.៤- ឯកសណ្ឋាននារីសម្រាប់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពល

### គំរូអាវដៃខ្លី អាវដៃវែង និងខោ

### អាវដៃខ្លី



# អាវដៃវែង



# ខោ



## ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ...៥៣...អនក្រ.បក.....ចុះថ្ងៃទី.....២......ខែ...មេសា......ឆ្នាំ...២០១៩.....

## ស្ដីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

### ២- គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែសម្រាប់បុរស

២.១- ខ្សែក្រវាត់



២.២- ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅ



២.៣- ស្បែកជើងឃ្លុបកវែង



២.៤- ស្រោមជើងពណ៌ខ្មៅ



## ឧបសម្ព័ន្ធទី៣

### នៃអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៨

### ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

**៣- គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែសម្រាប់នារី**

**៣.១- ខ្សែក្រវាត់**



**៣.២- ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅ**



**៣.៣- ស្បែកជើងឃ្លុបកវែង**



**៣.៤- ស្រោមជើងពណ៌ខ្មៅ**



**ឧបសម្ព័ន្ធទី៤**

**នៃអនុក្រឹត្យលេខ**...៥៣...អនក្រ.បក...**ចុះថ្ងៃទី**....២.......**ខែ**..មេសា......**ឆ្នាំ**..២០១៩.....

**ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ**

## ៤- គំរូមួករបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

### ៤.១- ថ្នាក់អគ្គនាយក



### ៤.២- ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន



### ៤.៣- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ



### ៤.៤- ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី



ឧបសម្ព័ន្ធទី៥

នៃអនុក្រឹត្យលេខ...៥៣...អនក្រ.បក....ចុះថ្ងៃទី....២.....ខែ...មេសា.....ឆ្នាំ..២០១៨...

ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

## ៥- គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

### ៥.១- ថ្នាក់អគ្គនាយក




### ៥.២- ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន



## ៥.៣- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ




## ៥.៤- ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី



## ឧបសម្ព័ន្ធទី៦

### នៃអនុក្រឹត្យលេខ...៥៣ អនក្រ.បក...ចុះថ្ងៃទី...២...ខែ...មេសា...ឆ្នាំ ២០១៨...

### ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

**៦. គំរូសញ្ញាសម្គាល់**

**៦.១. សញ្ញាសម្គាល់ជាប់ដៃអាវខាងស្តាំរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ**




**៦.២. សញ្ញាសម្គាល់ជាប់ដៃអាវខាងឆ្វេងរបស់អគ្គនាយកដ្ឋានធនធានរ៉ែ**



**៦.៣. សញ្ញាសម្គាល់ជាប់ដៃអាវខាងឆ្វេងសម្រាប់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពល**



**៦.៤. សញ្ញាសម្គាល់ចុងកអាវសម្រាប់អគ្គនាយកដ្ឋានធនធានរ៉ែ**



៦.៥- សញ្ញាសម្គាល់ចុងកអាវសម្រាប់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែ និងថាមពល



៦.៦- ស្លាកសម្គាល់ឈ្មោះមន្ត្រីរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែ




៦.៧- សញ្ញាសម្គាល់នគរបាលយុត្តិធម៌



## ឧបសម្ព័ន្ធទី៧

នៃអនុក្រឹត្យលេខ...៥៣ អនក្រ.បក...ចុះថ្ងៃទី...២......ខែ..មេសា......ឆ្នាំ..២០១៩....

## ស្ដីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

### ៧- គំរូឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែ

#### ៧.១- គំរូឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែសម្រាប់អគ្គនាយកដ្ឋានធនធានរ៉ែ



### ៧.២- គំរូឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចធនធានរ៉ែសម្រាប់អង្គភាពផ្សេងទៀតរបស់ក្រសួងរ៉ែនិងថាមពល

